ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D253/1/8

## តាមនាមប្រជាជនកម្ពុជា និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៣)

**អង្គបុរេជំនុំជម្រះ**

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម នៃយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 12 / 2017
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:កោសលុប**

**សេចក្តីសម្រេចលើសំណើរបស់ [redacted] សុំធ្វើមោឃភាពឯកសារ D114/164, D114/167, D114/170 និង D111/171**

**សហព្រះរាជអាជ្ញា:**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី មាស មុត:**
អាង ឧត្តម
Michael G. KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI


ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh
Original EN: 01544491-01544507

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "ពាក្យសុំរបស់ [redacted] សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171" ដែលសហមេធាវីការពារក្តី [redacted] (ដែលហៅថា "សហមេធាវីការពារក្តី" និង "អ្នកដាក់ពាក្យសុំ") បានដាក់កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ("សំណើសុំ")[1]។

## I. សេចក្តីផ្តើម

1. សំណើសុំត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៧ ("សេចក្តីសម្រេចបញ្ជូនសំណើសុំ")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ដោយចោទប្រកាន់ពីការចូលរួមរបស់អ្នកដាក់ពាក្យសុំ នៅក្នុងអំពើឧក្រិដ្ឋ ហើយបានស្នើឱ្យដាក់បទចោទប្រកាន់លើរូបគាត់ ពីបទនានាដែលក្នុងនោះមានបទធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3]។

3. នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដើម្បីឱ្យអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បំពេញកិច្ចស៊ើបសួរ ហើយបង្គាប់ពួកគេឱ្យ "កំណត់អត្តសញ្ញាណ ស្វែងរកទីលំនៅ និងធ្វើការស្តាប់ចម្លើយសាក្សី [...] ទាក់ទងនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោម ការស៊ើបអង្កេតរបស់តុលាការ"[4]។

---

[1] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក-កសចស ("សំណុំរឿង ០០៣"), ពាក្យសុំរបស់ [redacted] សុំឱ្យមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D253/1/3 ("សំណើរសុំ") ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧។

[2] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះ ទទួលយកសំណើសុំមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171 ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D253/1។

[3] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់សហព្រះរាជអាជ្ញា ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៣ ការជូនដំណឹងពីការដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[4] សំណុំរឿង ០០៣ ដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ D114 ទំព័រ ២ កថាខណ្ឌ គ។

4. នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ មាស មុត ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាការធ្វើទារុណកម្មនៅ "មន្ទីរសន្តិសុខផ្សេងៗ ជាពិសេស មន្ទីរសន្តិសុខស-២១"[5] ដែលស្ថិតនៅក្រោមទម្រង់នៃការទទួលខុសត្រូវនៃ "សហឧក្រិដ្ឋកម្មរួម ប្រភេទទី១ [ឬ] តាមរយៈការរៀបចំផែនការ ឬការបញ្ជា ឬក៏តាមរយៈការទទួលខុសត្រូវថ្នាក់លើ[6]។

5. នៅខែមករា និងកុម្ភៈ ឆ្នាំ២០១៦ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត បានបំពេញកិច្ចស៊ើបសួរមួយចំនួន ដោយបានកំណត់អត្តសញ្ញាណ និងស្វែងរកសាក្សី ហើយបានបង្កើតនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ("កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ D114/164")[7] [redacted] ("កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ D114/167")[8] ព្រំ ម៉ុន ("កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ D114/170"[9] [redacted] ("កំណត់ហេតុស្តាប់ចម្លើយសាក្សី ឯកសារ D114/171")[10] (ទាំងអស់គ្នាជា "សាក្សីដែលមានបញ្ហា") និង "កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានបញ្ហា")។ អ្នកស៊ើបអង្កេតរបស់ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានកត់ត្រាកិច្ចស៊ើបសួរ ទៅក្នុងកំណត់ហេតុនៃកិច្ចស៊ើបសួរចំនួនពីរ ("កំណត់ហេតុនៃកិច្ចស៊ើបសួរ") ដែលកំណត់ហេតុមួយនៅក្នុងខែកុម្ភៈ ("កំណត់ហេតុនៃកិច្ចស៊ើបសួរ ឯកសារ

---

[5] សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង របស់ [redacted] ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174 ទំព័រ ៤ យោងទៅរកដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៣, ៦៥ ដល់៦៦។

[6] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ៥

[7] សំណុំរឿង ០០៣ កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/164 ("កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/164")។

[8] សំណុំរឿង ០០៣, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/167 ("កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/167")។

[9] សំណុំរឿង ០០៣, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/170 ("កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/170")។

[10] សំណុំរឿង ០០៣, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/171 ("កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/171")។

D114/174")[11] និងមួយទៀតនៅក្នុងខែមីនា ឆ្នាំ២០១៦ ("កំណត់ហេតុនៃកិច្ចស៊ើបសួរ ឯកសារ D114/184")[12] (ទាំងអស់នេះជា "កំណត់ហេតុនៃកិច្ចស៊ើបសួរដែលមានបញ្ហា")។

6. នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ សហមេធាវីការពារក្តី បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងកំណត់ហេតុនៃកិច្ចស៊ើបសួរ និងកំណត់ហេតុនៃកិច្ចស៊ើបសួរពាក់ព័ន្ធ ដែលមានបញ្ហា ព្រោះបើតាមទស្សនៈរបស់សហមេធាវីការពារក្តី "បង្ហាញថា ក.ស.ច.ស. បានស្គាល់សាក្សីទាំងនេះ ដោយសារឈ្មោះសាក្សីទាំងនេះត្រូវបានរៀបរាប់ នៅក្នុងជីវប្រវត្តិដែលត្រូវបានអះអាងថា ធ្វើឡើងនៅស-២១ ដោយកម្មាភិបាលដែលត្រូវបានបោសសម្អាតពីខេត្តក្រចេះ។ ព័ត៌មាននេះបង្កឱ្យមានការព្រួយបារម្ភថា តើជីវប្រវត្តិស-២១ទាំងនេះ គឺជាភស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម ឬយ៉ាងណា ហើយប្រសិនបើដូច្នេះមែន ថាតើឯកសារទាំងនេះ អាចត្រូវបាន ក.ស.ច.ស យកមកប្រើប្រាស់ ក្នុងអំឡុងពេលស៊ើបអង្កេត និងត្រូវបានសហចៅក្រមស៊ើបអង្កេតយកមកធ្វើជាសំអាង ក្នុងការធ្វើសេចក្តីព្រាងដីកាលើកលែងការចោទប្រកាន់ ឬដីកាដំណោះស្រាយនៅក្នុងវិសាលភាពកម្រិតណាដែរ" ("សំណើសុំបំពេញកិច្ចស៊ើបសួរ")[13]។

7. នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីសម្រេចរួម លើសំណើសុំបំពេញកិច្ចស៊ើបសួរ ("សេចក្តីសម្រេចរួម")[14]។ នៅក្នុងសេចក្តីសម្រេចរួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេច ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានបញ្ហា៖ ថា ១) "[...]ដូច្នេះ ខ្ញុំយល់ឃើញថា គ្មានការធ្វើឱ្យប៉ះពាល់ ដល់ភស្តុតាងរបស់ [redacted] ឡើយ (ឯកសារ D114/164)"[15] ២) "គ្មានការចង្អុលបង្ហាញណាមួយឡើយ នៅក្នុងកំណត់ហេតុស្តា

[11] សំណុំរឿង ០០៣ កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D114/174 ("កំណត់ហេតុនៃកិច្ចស៊ើបសួរ ឯកសារ D114/174") ទំព័រ ៣ ដល់៤។

[12] សំណុំរឿង ០០៣ កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D114/184 ("កំណត់ហេតុនៃកិច្ចស៊ើបសួរ ឯកសារ D114/184") ទំព័រ ២ ដល់៣។

[13] សំណុំរឿង ០០៣, សំណើរបស់ [redacted] សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងឯកសារ D114/174, D114/184 និងការស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ និងការប្រើប្រាស់ជាសក្ខានុភូត នៃភស្តុតាងដែលទទួលបាន តាមរយៈទារុណកម្ម ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧ ឯកសារ D227 ("សំណើសុំបំពេញកិច្ចស៊ើបសួរ") កថាខណ្ឌ ១។

[14] សំណុំរឿង ០០៣ សេចក្តីសម្រេចរួមលើសំណើរបស់ [redacted] សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទង ការប្រើប្រាស់ជាសក្ខានុពល នៃភស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D251។

[15] សេចក្តីសម្រេចរួម កថាខណ្ឌ ៤៨។



PRE-TRIAL CHAMBER E.C.C.C.

01548569



ប់ចម្លើយ (ឯកសារ D114/167) [...] ថា ព័ត៌មានដែលមានជាប់ពាក់ព័ន្ធ នឹងការធ្វើទារុណកម្មណាមួយ ត្រូវបានបង្ហើបប្រាប់ដល់សាក្សីនោះ"[16] ៣) "គ្មានការចង្អុលបង្ហាញណាមួយ នៅក្នុង [...] កំណត់ហេតុស្តាប់ (ឯកសារ D114/170) ថា ចៅក្រមស៊ើបអង្កេតបានចែករំលែកព័ត៌មាន ដែលមានជាក់ពាក់ព័ន្ធ នឹងការធ្វើទារុណកម្មណាមួយ ជាមួយនឹងសាក្សីឡើយ"[17] និងចុងក្រោយ ៤) ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/171 "នៅក្នុងការស្តាប់ចម្លើយនោះ អ្នកស៊ើបអង្កេតបានយោងដល់ជីវប្រវត្តិពីមន្ទីរស-២១ នៅពេលសាកសួរសាក្សី អំពីមុខតំណែងប្តីរបស់គាត់ ក្នុងគណៈកម្មាធិការតំបន់ [...] ខ្ញុំចាត់ទុកព័ត៌មាននោះថា ជាការសន្មតដូចគ្នា នៃការធ្វើទារុណកម្ម [...] ដែលភ្ជាប់ទៅនឹងចម្លើយសារភាពនៅមន្ទីរស-២១។ [...]។ កំហុសនេះត្រូវបានកែប្រែយ៉ាងងាយស្រួល ដោយមិនគិតដល់ចម្លើយទី៤៦ រហូតដល់ចប់។ ខ្ញុំ [...] មិនគោរពតាមចម្លើយទី៤៦ រហូតដល់ចប់នៃឯកសារ D114/171 សម្រាប់ដំណាក់កាលបន្តទៀត នៃកិច្ចដំណើរការនីតិវិធីឡើយ"[18]។

8. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់សំណើសុំ នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ស្នើសុំមោឃភាពកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានបញ្ហា[19] ដែលសំណើសុំនេះត្រូវបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជូនមកអង្គបុរេជំនុំជម្រះនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧[20]។

9. នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានផ្តល់រយៈពេលដប់ថ្ងៃដល់សហមេធាវីការពារក្តី ដើម្បីដាក់សំណើសុំរបស់ពួកគេ នៅចំពោះអង្គជំនុំជម្រះ[21]។ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ និងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ មេធាវីការពារក្តីបានដាក់សំណើសុំ ជាភាសាអង់គ្លេស

---

[16] សេចក្តីសម្រេចរួម កថាខណ្ឌ ៥១។

[17] សេចក្តីសម្រេចរួម កថាខណ្ឌ ៥៤ ដល់៥៥។

[18] សេចក្តីសម្រេចរួម កថាខណ្ឌ ៥៨ ដល់៥៩។

[19] សំណុំរឿង ០០៣ ពាក្យសុំរបស់ [redacted] ឡើងទៅអង្គបុរេជំនុំជម្រះ អំពីសំណើសុំមោឃភាពឯកសារ D114/164, D114/167, D114/170 និង D114/171, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D253។

[20] សេចក្តីសម្រេចបញ្ជូនបន្ត។

[21] ការជូនដំណឹងរបស់មន្ត្រីសំណុំរឿង ការបង្គាប់របស់អង្គបុរេជំនុំជម្រះដល់ភាគីនានា តាមរយៈសារអេឡិចត្រូនិក នៅក្នុងសំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក-កសចស (អបជ៣៣) ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៧។



PRE-TRIAL CHAMBER
E.C.C.C

01548570



និងភាសាខ្មែរជាបន្តបន្ទាប់[22]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ (“ចម្លើយតប”)[23]។ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ សហមេធាវីការពារក្តីបានដាក់សំណើសុំពន្យាពេល ហើយសុំដាក់ការឆ្លើយតបរបស់ខ្លួន ជាភាសាអង់គ្លេសជាមុនសិន ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់ជូនតាមក្រោយ[24] ដែលសំណើនេះត្រូវបានអនុញ្ញាតនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧[25]។ ការឆ្លើយតបរបស់សហមេធាវីការពារក្តី ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស នៅថ្ងៃទី១២ ខែកញ្ញា ហើយជាភាសាខ្មែរនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ (“ការឆ្លើយតប”)[26]។

## III. ភាពអាចទទួលយកបាន

10. សហមេធាវីការពារក្តីបានដាក់សំណើសុំ អនុលោមតាមវិធាន៧៦ នៃវិធានផ្ទៃក្នុង ដោយអះអាងថា កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមានបញ្ហា គឺមានវិការៈ ហើយថាការពឹងផ្អែកទៅលើភស្តុតាងខុសច្បាប់ គឺរំលោភបំពានទៅលើសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

11. វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុងបានបង្គាប់ថា អង្គបុរេជំនុំជម្រះអាចប្រកាសថា សំណើសុំមោឃភាពមួយ មិនអាចទទួលយកបានក្នុងករណីដែលសំណើសុំនោះ៖ ១) មិនបានបង្ហាញហេតុផល

[22] សូមមើលជើងទំព័រ ១ ខាងលើ។

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ [redacted] សុំធ្វើមោឃភាពកំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សីចំនួនបួន ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D253/1/4។

[24] សំណុំរឿង ០០៣ សំណើរបស់ [redacted] សុំពន្យាពេលនៃការឆ្លើយតប ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់ [redacted] សុំមោឃភាពកំណត់ហេតុ នៃការស្តាប់ចម្លើយចំនួនបួន និងសំណើសុំដាក់ការឆ្លើយតបនេះ ជាភាសាអង់គ្លេស ដោយដាក់ការបកប្រែជាភាសាខ្មែរតាមក្រោយ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D253/1/5។

[25] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ [redacted] សុំពន្យាពេលនៃការឆ្លើយតប ទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់ [redacted] សុំមោឃភាពកំណត់ហេតុ នៃការស្តាប់ចម្លើយចំនួនបួន និងសំណើសុំដាក់ការឆ្លើយតបនេះ ជាភាសាអង់គ្លេស ដោយដាក់ការបកប្រែជាភាសាខ្មែរតាមក្រោយ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D253/1/6 ។

[26] សំណុំរឿង ០០៣ ការឆ្លើយតបរបស់ [redacted] ចំពោះចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងពាក្យសុំធ្វើមោឃភាពរបស់ [redacted] នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួនបួន ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D253/1/7 ជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧។



PRE-TRIAL CHAMBER ECCC

គ្រប់គ្រាន់ ២) ពាក់ព័ន្ធជាមួយដីកាដែលត្រូវប្ដឹងឧទ្ធរណ៍ ឬ៣) គ្មានមូលដ្ឋានច្បាស់លាស់។ ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវស្វែងរកថាតើ សំណើសុំមោឃភាព៖ ១) បានបញ្ជាក់ច្បាស់នូវផ្នែកនៃកិច្ចដំណើរការនីតិវិធី ដែលមានវិសោធនកម្មទៅលើសិទ្ធិ និងផលប្រយោជន៍របស់អ្នកដាក់ពាក្យសុំ ឬយ៉ាងណា ២) បញ្ជាក់ច្បាស់នូវវិសោធនកម្ម និង៣) ក្នុងករណីចាំបាច់ បន្ថែមភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការចោទប្រកាន់[27]។

12. អង្គបុរេជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌតាមវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញ។ កំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលមានបញ្ហា មិនមានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្ដឹងឧទ្ធរណ៍ឡើយ។ មិនមានអ្វីមួយនៅក្នុងសំណើសុំបង្ហាញថា សំណើសុំនេះគ្មានមូលដ្ឋានច្បាស់លាស់ ទាំងតាមអង្គហេតុ ឬអង្គច្បាប់ដែលធ្វើឱ្យសំណើសុំនេះ មិនមានលទ្ធភាពទទួលបានជោគជ័យនោះ ឡើយ។ អង្គជំនុំជម្រះយល់ឃើញបន្ថែមទៀតថា សំអាងហេតុដែលមាននៅក្នុងសំណើសុំនេះ មានលក្ខណៈគ្រប់គ្រាន់ដោយសារតែសំណើសុំមានការលើកឡើងដែលស៊ីសង្វាក់គ្នាយ៉ាងសមហេតុផល ដែលមានការគាំទ្រដោយសំអាងផ្លូវច្បាប់ ដែលមូលដ្ឋាននៃសំអាងផ្លូវច្បាប់នោះមានចែងច្បាស់ ឬដែលសម្ភារៈអង្គហេតុមានច្បាស់លាស់ នៅក្នុងសំណុំរឿង។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា សំណើសុំនេះអាចទទួលយកបាន។

## IV. ច្បាប់ជាធរមាន

13. ការធ្វើមោឃភាពអាចប្រមើលមើលដឹងថាមានចែង នៅក្នុងវិធាន ៤៨ នៃវិធានផ្ទៃក្នុង ដែលចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគី ដែលដាក់ពាក្យសុំប៉ុណ្ណោះ។

14. ហេតុដូច្នេះ ការពិនិត្យទៅលើសំណើសុំមោឃភាពតម្រូវ៖ (១) ជាដំបូងការពិចារណាលើកំហុសនីតិវិធី និង(២) បន្ទាប់មកទៀត អត្ថិភាពនៃការខូចខាតទៅលើភាគីម្ចាស់សំណើ ប្រសិនបើមានកំហុស

---

[27] សេចក្ដីពិចារណាលើសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរ និងដីកាទាក់ទងនឹងទំនប់កង្កួត ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D345/1/6 កថាខណ្ឌ ៧។

នីតិវិធីមែន[28]។ អនិយ័តភាពផ្នែកនីតិវិធី ដែលមិនបង្កជាព្យសនកម្មដល់អ្នកដាក់ពាក្យសុំ មិននាំទៅដល់ការធ្វើមោឃភាពទេ[29]។

## V. អង្គសេចក្តី

### ក. សារណា

### *១ សំណើសុំ៖*

15. សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាព កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/164, D114/167, D114/170 និងឯកសារ D114/171[30] ហើយចោទប្រកាន់ពីកំហុសឆ្គងនីតិវិធី ដោយផ្អែកលើមូលដ្ឋានចំនួនពីរ ដោយអះអាងថា "[...] ក.ស.ច.ស. បានរំលោភបំពានទៅលើអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ("អនុសញ្ញា CAT")[31] ដូច្នេះហើយក៏បំពានទៅលើច្បាប់ជាធរមានរបស់កម្ពុជា តាមរយៈ៖ ១) ពឹងផ្អែកទៅលើប្រវត្តិរូបដែលទទួលបាន តាមរយៈការធ្វើទារុណកម្មនៅស-២១ ("មូលដ្ឋានទីមួយ")[32] និង ២) ដាក់កំណត់ហេតុស្តាប់ចម្លើយដែលទាញចេញពីការធ្វើទារុណកម្ម ចូលទៅក្នុងសំណុំរឿង ("មូលដ្ឋានទីពីរ"[33])[34]។ សហមេធាវី

---

[28] សំណុំរឿង ០០៣ (PTC20), សាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះ ទទួលពិនិត្យនិងចាត់ការលើសំណើចំនួនពីរ សុំមោឃភាពកិច្ចស៊ើបសួរ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D134/1/10 ("សាលដីកាលើសំណើចំនួនពីររបស់ [redacted]") កថាខណ្ឌ ២៥ យោងទៅរកសំណុំរឿង ០០២ (អបជ០៦) សាលដីកាសលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងដីកាសម្រេចបដិសេធ សំណើសុំមោឃភាព ឯកសារ D55/I/8 ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា") កថាខណ្ឌ ៣៤។

[29] សាលដីកាលើសំណើចំនួនពីររបស់ [redacted], កថាខណ្ឌ ២៦ យោងទៅរក សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចបដិសេធ សំណើសុំមោឃភាពរបស់អៀង ធីរិទ្ធ ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០១០, D263/6 កថាខណ្ឌ ២១។

[30] សំណើសុំ កថាខណ្ឌ ៣២។

[31] អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិឬដាក់ទណ្ឌកម្មដទៃទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧ 1465 ("អនុសញ្ញា CAT")។

[32] សំណើសុំ កថាខណ្ឌ ៥ ដល់១៧។

[33] សំណើសុំ កថាខណ្ឌ ១៨ ដល់៣១។

[34] សំណើសុំ កថាខណ្ឌ ៣១។ សំណើសុំ កថាខណ្ឌ ៤ និង ៣២។

ការពារក្តីបានអះអាងបន្ថែមទៀតថា "វិការៈទាំងនេះរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ របស់លោក មាស មុត" ។

16. ដើម្បីគាំទ្រដល់មូលដ្ឋានទីមួយ សហមេធាវីការពារក្តីបានលើកឡើង នូវទឡ្ហីករណ៍សំខាន់ចំនួនពីរ ដែលរួមមាន៖ "ព័ត៌មានដែលត្រូវបានប្រើជាតម្រុយ នៃកិច្ចស៊ើបសួរ គឺជាភស្តុតាង" ("ទឡ្ហីករណ៍ ក")[35] និង "ការសំអាងលើភស្តុតាង ដែលបានមកពីទារុណកម្ម ជាភស្តុតាងតម្រុយ គឺផ្ទុយពីសនិទានភាពគោលនយោបាយ នៅពីក្រោយវិធានបដិសេធភស្តុតាង" ("ទឡ្ហីករណ៍ ខ")[36]។ នៅក្នុងទឡ្ហីករណ៍ ក សហមេធាវីការពារក្តីបានលើកឡើងថា "ព័ត៌មានដែលត្រូវបានប្រើជាតម្រុយនៃកិច្ចស៊ើបសួរ គឺជាភស្តុតាង៖ វាជាចំណងភ្ជាប់នៅក្នុងខ្សែចង្វាក់នៃភស្តុតាង ដែលគាំទ្រ ឬបដិសេធអង្គហេតុណាមួយ"[37] ហើយថា "ព័ត៌មានដែលបញ្ជាក់ពីគុណភាព និងភាពអាចជឿជាក់បាននៃភស្តុតាង ក៏ជាភស្តុតាងសំខាន់ផងដែរ"[38] ហើយសហមេធាវីការពារក្តីអះអាងថា "និយមន័យនៃភស្តុតាង ដែលមិនរាប់បញ្ចូលតម្រុយនៃកិច្ចស៊ើបសួរ [...] គឺជានិយមន័យចង្អៀតហួសហេតុពេក [...] មិនអាចត្រូវបានប្រើប្រាស់ ដើម្បីបញ្ចៀសការអនុវត្តវិធានបដិសេធភស្តុតាង ដែលចែងក្នុងអនុសញ្ញា CAT"[39]។ សហមេធាវីការពារក្តីអះអាងបន្ថែម នៅក្នុងទឡ្ហីករណ៍ ខ ថា "ការប្រើប្រាស់ភស្តុតាងដែលបានមកពីទារុណកម្ម សម្រាប់ហេតុផលណាក៏ដោយ គឺផ្តល់ភាពស្របច្បាប់ដល់ការប្រើប្រាស់ទារុណកម្ម និងលើកកម្ពស់ទារុណកម្ម"[40] ហើយថា "គោលបំណងនៃវិធានបដិសេធភស្តុតាង គឺការធ្វើឱ្យទារុណកម្មគ្មានតម្លៃ មិនមែនជាការធានាថា ការផ្តន្ទាទោសត្រូវតែផ្អែកលើភស្តុតាងដែលអាចជឿជាក់នោះទេ"[41]។ សហមេធាវីការពារក្តីបានអះអាងថា ទោះបីជា "លទ្ធភាពនៃការប្រើប្រាស់ភស្តុតាង ដែលបានមកពីទារុណកម្មតែមួយគត់ តាមមាត្រា ១៥ នៃអនុសញ្ញា CAT គឺការយកវាមកធ្វើជាភស្តុតាង ប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ ពីបទទារុណកម្ម ជាភ

[35] សំណើសុំ កថាខណ្ឌ ៥ ដល់៩។

[36] សំណើសុំ ផ្នែក "ខ" និងកថាខណ្ឌ ១០ ដល់១៧។

[37] សំណើសុំ កថាខណ្ឌ ៥។

[38] សំណើសុំ កថាខណ្ឌ ៦។

[39] សំណើសុំ កថាខណ្ឌ ៧។

[40] សំណើសុំ កថាខណ្ឌ ១២។

[41] ដូចជើងទំព័រខាងលើ។

ស្តុតាងបង្ហាញថាចម្លើយនោះ ត្រូវបានធ្វើឡើងក្រោមទារុណកម្ម"[42] "ជីវប្រវត្តិទាំងនោះមិនត្រូវបានប្រើ ដើម្បីបង្ហាញថាជីវប្រវត្តិទាំងនោះ ត្រូវបានធ្វើឡើងក្រោមទារុណកម្មនោះទេ"[43]។ បន្ទាប់មកសហមេធាវីការពារក្តី បានយោងទៅរកយុត្តិសាស្ត្រអន្តរជាតិ និងអត្ថបទស្រាវជ្រាវ ហើយបញ្ជាក់ថា "ការដកចេញនូវការលើកទឹកចិត្ត ដល់ការប្រើប្រាស់ទារុណកម្ម គឺមានសារៈសំខាន់ជាពិសេស នៅប្រទេសកម្ពុជា"[44]។ សហមេធាវីការពារក្តីបានសន្និដ្ឋានថា "សនិទានភាពគោលនយោបាយ នៅពីក្រោយមាត្រា ១៥ នៃអនុសញ្ញា CAT ស្តីពីការបំបាត់ការលើកទឹកចិត្ត ឱ្យមានទារុណកម្ម និងការការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី បង្ហាញឱ្យឃើញថា ក.ស.ច.ស. មិនត្រូវសំអាងលើជីវប្រវត្តិស-២១ ដែលបានមកពីទារុណកម្ម ធ្វើជាតម្រុយកិច្ចស៊ើបសួរ និងបង្ហាញឱ្យឃើញថា គ្មានកំណត់ហេតុនៃការស្តាប់ចម្លើយណាមួយ ដែលជាផលនៃតម្រុយនេះ អាចត្រូវបានប្រើប្រាស់ឡើយ"[45]។

17. បន្ទាប់មក សហមេធាវីការពារក្តី បានបកស្រាយនូវទឡ្ហីករណ៍របស់ខ្លួន ដើម្បីគាំទ្រដល់មូលដ្ឋានទីពីរ សម្រាប់ការចោទប្រកាន់ពីវិការៈនីតិវិធី នៅក្រោមផ្នែក "គ" នៃបណ្តឹងឧទ្ធរណ៍ នៅពេលដែលពួកគេបានលើកទឡ្ហីករណ៍ថា "មាត្រា ១៥ នៃអនុសញ្ញា CAT អនុវត្តចំពោះភស្តុតាងដែលកើតចេញពី ភស្តុតាងបានមកពីទារុណកម្ម ("ទឡ្ហីករណ៍ គ")[46]។ សហមេធាវីការពារក្តីបានលើកឡើងថា "ទីមួយ ការពិនិត្យលើឯកសារការងារត្រៀមរៀបចំ នៃអនុសញ្ញា CAT ពុំគាំទ្រការសន្និដ្ឋានដែលថា មានចេតនាដកភស្តុតាងដែលកើតចេញ ពីភស្តុតាងដែលបានមកពីទារុណកម្មចេញឡើយ"[47] ហើយ "ទីពីរការដែលថាប្រព័ន្ធច្បាប់ស៊ីវិល គាំទ្រការដាក់ភស្តុតាងដោយសេរី មិនមែនមានន័យថាប្រព័ន្ធបែបនេះ អនុញ្ញាតជាសាកលចំពោះ ការដាក់ភស្តុតាងដែលកើតចេញ ពីភស្តុតាង

[42] សំណើសុំ កថាខណ្ឌ ១៣។

[43] ដូចជើងទំព័រខាងលើ សូមមើលផងដែរ សំណើសុំ កថាខណ្ឌ ៣(ក)៖ ក.ស.ច.ស. បានប្រើប្រាស់ជីវប្រវត្តិ ស-២១ ដែលបានមកពីការធ្វើទារុណកម្ម ក្នុងតម្លៃជាភស្តុតាង"។ កថាខណ្ឌ ៣(ខ) "ធ្វើជាតម្រុយភស្តុតាង" និងកថាខណ្ឌ ៨ "ដើម្បីស្វែងរកសាច់ញាតិរបស់មនុស្ស ដែលបានទទួលរងទារុណកម្មនៅមន្ទីរ ស-២១ និង [...] អាសយដ្ឋាននៅក្នុងជីវប្រវត្តិទាំងនោះ ដើម្បីស្វែងរកមនុស្សទាំងនេះ"។

[44] សំណើសុំ កថាខណ្ឌ ១៣ ដល់១៦។

[45] សំណើសុំ កថាខណ្ឌ ១៧។

[46] សំណើសុំ កថាខណ្ឌ ១៨ ដល់៣១។

[47] សំណើសុំ កថាខណ្ឌ ១៨, ២១។

បានមកពីទារុណកម្មឡើយ”[48]។ សហមេធាវីការពារក្តីបានបន្ថែមថា “ការពិនិត្យលើប្រភពអន្តរជាតិបង្ហាញថា វិធានបដិសេធភស្តុតាង អនុវត្តចំពោះភស្តុតាងដែលកើតចេញពី ភស្តុតាងបានមកពីទារុណកម្ម”[49]។

18. ចំពោះការចោទប្រកាន់ពីព្យសនកម្មដែលកើតមាននោះ សហមេធាវីការពារក្តីបានលើកឡើងថា “សិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ត្រូវបានការពារដោយកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ២១” ត្រូវបានរំលោភបំពាន[50]។

## ២ ចម្លើយតប

19. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើដល់អង្គបុរេជំនុំជម្រះ “ច្រានចោលសំណើសុំមោឃភាពនេះ” ដោយសន្និដ្ឋានថា “មិនមានច្បាប់ ឬគោលនយោបាយជាមូលដ្ឋានណា នៃវិធានបដិសេធភស្តុតាង របស់អនុសញ្ញា CAT គាំទ្រដល់ការហាមឃាត់ការប្រើប្រាស់ប្រវត្តិរូបមន្ទីរស-២១ ជាតម្រុយស៊ើបអង្កេតឡើយ”[51]។

20. ឆ្លើយតបទៅនឹងមូលដ្ឋានទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា “ការពឹងផ្អែកទៅលើឯកសារដែលទទួលបាន ដោយការធ្វើទារុណកម្ម ធ្វើជាតម្រុយស៊ើបអង្កេត មិនអាចចាត់ទុកថាជា “ការប្រើប្រាស់ធ្វើជាភស្តុតាង” សម្រាប់គោលបំណងនៃអនុសញ្ញា CAT ឡើយ”[52]។ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការប្រើប្រាស់ជីវប្រវត្តិពីមន្ទីរស-២១ ដើម្បីកំណត់អត្តសញ្ញាណរបស់សាក្សី គឺមិនដូចគ្នានឹង “ប្រវត្តិរូប [...] មិនបានទោទន់ទៅរកភស្តុតាង ដោយភាគីណាមួយឡើយ ហើយក៏មិនត្រូវបានទុកចិត្ត ចំពោះការពិតលើវានោះដែរ”[53]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានអះអាងផងដែរថា សហមេធាវីការពារក្តីបានផ្តល់ “និយមន័យទូលំទូលាយមួយដែលបង្កន់ និងដែលហួសក្រៃពេកនៃភស្តុតាង”[54] ។ បន្ថែមលើនេះសហព្រះរាជអាជ្ញាអន្តរជាតិ

---

[48] សំណើសុំ កថាខណ្ឌ ១៨, ២២។

[49] សំណើសុំ កថាខណ្ឌ ២៤ ដល់២៥, ២៧ ដល់២៩។

[50] សំណើសុំ កថាខណ្ឌ ៤, ៩, ១៧, ៣១ ដល់៣២។

[51] ចម្លើយតប កថាខណ្ឌ ៧១។

[52] ចម្លើយតប កថាខណ្ឌ ២៦ ដល់៣៣។

[53] ចម្លើយតប កថាខណ្ឌ ២៨ ដល់៣០។

[54] ចម្លើយតប កថាខណ្ឌ ៣១។

បានលើកឡើងថា “បើសិនជាមានសំណួរនៅសេសសល់ណាមួយ ដែលថាតម្រុយស៊ើបអង្កេត (ការដឹកនាំការស៊ើបអង្កេត) មិនត្រូវបានក្តោបបញ្ចូលដោយមាត្រា ១៥ នៃអនុសញ្ញា CAT ទេនោះ មាត្រានោះដោយខ្លួនឯងផ្ទាល់ បានធ្វើឱ្យវាច្បាស់ដោយការមិនគ្រាន់តែ ហាមឃាត់ពីអត្ថិភាពនៃភស្តុតាងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការយកមកប្រើវិញ ជាភស្តុតាង”[55]។

21. ដើម្បីឆ្លើយតបចំពោះមូលដ្ឋានទីពីរ របស់សហមេធាវីការពារក្តី សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង នូវទឡ្ហីករណ៍សំខាន់ៗចំនួនពីរ ដែលក្នុងនោះរួមមាន ១) “មាស មុត មិនបានបង្ហាញថាភស្តុតាងរាយរង ត្រូវបានហាមឃាត់ដោយមាត្រា ១៥ នៃអនុសញ្ញា CAT ឬដោយច្បាប់ត្រួតពិនិត្យផ្សេងៗទៀតនោះទេ”[56] និង ២) “ការអនុញ្ញាតភស្តុតាងរាយរង ក្នុងបរិបទពិសេសនៃអ.វ.ត.កនេះ មិនរំលោភបំពានលើសនិទានភាពគោលនយោបាយណាមួយ នៅពីក្រោយវិធានបដិសេធភស្តុតាងនោះឡើយ”[57]។ នៅក្នុងទឡ្ហីករណ៍ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់ថា “មាស មុត [...] បានទទួលថា “មាត្រា១៥នៃអនុសញ្ញា CAT គឺមិនមានចែងពីភស្តុតាងរាយរង””[58] ហើយបន្ទាប់មកបានលើកឡើងទៀតថា “មិនទាំងវិធានផ្ទៃក្នុង របស់អ.វ.ត.ក មិនទាំងច្បាប់របស់កម្ពុជា បានលើកឡើងពីការប្រើប្រាស់នូវ ភស្តុតាងរាយរងនោះទេ”[59]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា “កំណត់ហេតុស្តាប់ចម្លើយរាយរង មិនត្រូវបានធ្វើឡើងមកពីលទ្ធផលនៃអំពើទារុណកម្មនោះទេ ហើយដូច្នេះវាមិនត្រូវបានគ្រប់គ្រង ដោយភាសាងាយយល់នៃមាត្រា ១៥ នោះទេ”[60] ហើយ “នៅក្រោមន័យធម្មតា នៃពាក្យពេចន៍របស់ខ្លួន មាត្រា ១៥ អនុវត្តបានតែចំពោះ កំណត់ហេតុស្តាប់ចម្លើយខ្លួនឯងផ្ទាល់ ដែលត្រូវបានធ្វើឡើងមកពីលទ្ធផល នៃអំពើទារុណកម្ម”[61]។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា “មិនមានវិធាននារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបច្ចុប្បន្ននេះ ហាមឃាត់ភស្តុតាងរាយរងនោះទេ”[62] ហើយថាសហមេធាវី

[55] ចម្លើយតប កថាខណ្ឌ ៣៣។

[56] ចម្លើយតប កថាខណ្ឌ ៣៤ ដល់៥៣។

[57] ចម្លើយតប កថាខណ្ឌ ៥៤ ដល់៦៦។

[58] ចម្លើយតប កថាខណ្ឌ ៣៥ យោងលើ សំណើសុំ កថាខណ្ឌ ២១។

[59] ចម្លើយតប កថាខណ្ឌ ៣៦។

[60] ចម្លើយតប កថាខណ្ឌ ៣៩។

[61] ចម្លើយតប កថាខណ្ឌ ៤១។

[62] ចម្លើយតប កថាខណ្ឌ ៥២។

ការពារក្តីមិនបាន "បង្ហាញអំពីការឯកភាពគ្នាជាអន្តរជាតិណាមួយ កុំថាឡើយវិធានអាជ្ញាបញ្ញាទាក់ទងនឹងភាពអាចអនុវត្តបាន នៃមាត្រា១៥ ចំពោះភស្តុតាងរាយរង"[63]។ នៅក្នុងទឡ្ហីករណ៍ទីពីររបស់គាត់ ដើម្បីដោះស្រាយចំពោះមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់ថា "ជាការសមស្របក្នុងការពិចារណាទៅលើ សនិទានភាពគោលនយោបាយនៅពីក្រោយវិធានបដិសេធភស្តុតាង នៃមាត្រា១៥ ដើម្បីធ្វើការសម្រេចថាតើ ភស្តុតាងរាយរងគួរត្រូវបានហាមឃាត់ដែរឬទេ"[64] ហើយបានអនុម័តនូវទស្សនៈដែលថា "មិនមានតម្លៃរាំងណាត្រូវបដិសេធភស្តុតាងចេញពីកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការកម្ពុជាឡើយ"[65]។ បើតាមទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ "សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី នឹងត្រូវបានគាំទ្រដោយការប្រើប្រាស់ រាល់ភស្តុតាងដែលអាចរកបានទាំងអស់ ដែលមិនត្រូវបានហាមឃាត់ដោយផ្ទាល់ ដើម្បីកំណត់ការពិតនៃអង្គហេតុនានា នៅក្នុងរឿងក្តី ០០៣"[66]។

22. ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា "មោឃភាពនៅក្នុងកាលៈទេសៈទាំងនេះ គឺមិនមែនជាដំណោះស្រាយដ៏ត្រឹមត្រូវឡើយ"[67] ដោយសារតែ "មិនមានសិទ្ធិណាមួយរបស់ មាស មុត តាមកតិកាសញ្ញា ICCPR ត្រូវបានរំលោភដោយវត្តមាន កំណត់ហេតុស្តាប់ចម្លើយទាំងនោះ នៅក្នុងសំណុំរឿងនេះ ដោយសារតែភាគីទាំងអស់ឯកភាពថា ភស្តុតាងដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងនោះ មិនជាប់ប្រឡាក់ដោយទារុណកម្មទេ"[68] ដូច្នេះនឹងមិន "ប៉ះពាល់ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី"[69] ហើយ "ការប្រើប្រាស់ប្រវត្តិរូបស-២១ [...] ត្រូវតែពិនិត្យមើលក្នុងអាណត្តិ និងមុខងាររបស់អ.វ.ត.ក ដ៏ទូលំទូលាយជាង"[70]។

---

[63] ចម្លើយតប កថាខណ្ឌ ៥៣។

[64] ដូចជើងទំព័រខាងលើ ៥៤។

[65] ចម្លើយតប កថាខណ្ឌ ៥៩ យោងទៅរក Michael P. Scharg Tainted Provenance: When, if Ever, Should Torture Evidence Be Admissible, ឆ្នាំ ២០០៨ ទំព័រ ១៥២។

[66] ចម្លើយតប កថាខណ្ឌ ៦៥។

[67] ចម្លើយតប កថាខណ្ឌ ៦៧ ដល់៧០។

[68] ចម្លើយតប កថាខណ្ឌ ៦៧។

[69] ចម្លើយតប កថាខណ្ឌ ៧០។

[70] ចម្លើយតប កថាខណ្ឌ ៦៨។

### *ការឆ្លើយតប*

23. នៅក្នុងការឆ្លើយតប សហមេធាវីការពារក្ដីបញ្ជាក់សាជាថ្មីថា ព័ត៌មានដែលបានប្រើប្រាស់ជាតម្រុយក្នុងការស៊ើបអង្កេតគឺជាភ័ស្តុតាង ពីព្រោះថា ប្រសិនបើវាពុំមែនដោយសារ "ជីវប្រវត្តិ ស-២១ សាក្សីក៏មិនត្រូវបានរកឃើញដែរ"[71] ហេតុដូច្នេះ វាបង្ហាញឲ្យឃើញនូវអត្ថិភាពនៃ "ចំណងភ្ជាប់ [...] ដែលមានគោលបំណងបង្ហាញ ឬ បដិសេធអង្គហេតុមួយ" ។ ពួកគេអះអាងថា "មាត្រា ១៥ នេះមិនកំណត់ព្រំដែនពាក្យ*កិច្ចដំណើរការនីតិវិធី*ឲ្យនៅត្រឹមតែការជំនុំជម្រះនោះទេ ហើយក៏មិនកំណត់ព្រំដែនពាក្យ *ការយកមកប្រើ* ឲ្យនៅត្រឹមតែការប្រើប្រាស់នៅក្នុងការជំនុំជម្រះនោះដែរ" ហេតុដូច្នេះ ពួកគេសំអាងលើប្រវត្តិរូប ស-២១ នៅក្នុង "ដំណាក់កាលស៊ើបសួរមុនការជំនុំជម្រះ"[72] ដោយ "អ្នកស៊ើបអង្កេត ក.ស.ច.ស នៅពេលអនុវត្តភារកិច្ចស៊ើបសួរដែលត្រូវបានចាត់តាំងឲ្យគាត់ [...] ដែលជាធម្មតាត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយ [...] អាចជា*ការយកមកប្រើ*នូវភ័ស្តុតាងបែបនេះក្នុងគោលបំណងអនុវត្តកិច្ចស៊ើបសួរ"[73]។

24. សហមេធាវីការពារក្ដីអះអាងថា ដោយហេតុថា "កំណត់ហេតុនៃការស្ដាប់ចម្លើយចំនួនបួន នឹងមិនមាននោះទេ បើមិនមានជីវប្រវត្តិ ស-២១" វាគឺជាភ័ស្តុតាង "*ធ្វើឡើងដោយសារលទ្ធផលនៃភ័ស្តុតាងដែលបានពីទារុណកម្ម*"[74]។ ពួកគេបានបញ្ជាក់ថា "ការហាមឃាត់ការធ្វើទារុណកម្មដោយអនុសញ្ញា CAT គឺជាបទដ្ឋាន*អាជ្ញាព្រឹត្ត*នៃច្បាប់អន្តរជាតិដែលគ្របដណ្ដប់លើការហាមឃាត់ [...] មិនឲ្យប្រើប្រាស់ភ័ស្តុតាងដេលទទួលបានពីភ័ស្តុតាងបានពីទារុណកម្ម"[75] "ដែលជាសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាគឺជារដ្ឋភាគី"[76] ហេតុដូច្នេះហើយ "ក.ស.ច.ស និងអង្គជំនុំជម្រះទាំងឡាយត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញកម្ពុជា និងអនុសញ្ញា CAT"[77]។ ពួកគេជំទាស់ថា "ភាសាងាយយល់នៃមាត្រា ១៥ កម្មវត្ថុ និងគោលបំណងនៃអនុសញ្ញា CAT និងបទដ្ឋានជាតិ និងអន្តរជាតិហាមឃាត់ការប្រើប្រាស់ភ័ស្តុតាងដែលទទួលបានពីភ័ស្តុតាងបានទីទារុណកម្មនៅក្នុងកិច្ចដំណើរ

[71] ការឆ្លើយតប កថាខណ្ឌ ៩។

[72] ការឆ្លើយតប កថាខណ្ឌ ១៥។

[73] ការឆ្លើយតប កថាខណ្ឌ ១៣, កថាខណ្ឌ ១៥ ដល់ កថាខណ្ឌ ១៦។

[74] ដូចខាងលើ ២៥។

[75] ការឆ្លើយតប កថាខណ្ឌ ២៨។

[76] ការឆ្លើយតប កថាខណ្ឌ ៣៧។

[77] ការឆ្លើយតប កថាខណ្ឌ ៣៧។



PRE-TRIAL CHAMBER E.C.C.C

ការនីតិវិធីតុលាការលើកលែងតែការប្រើប្រាស់ភ័ស្តុតាងនោះគឺដើម្បីប្រឆាំងនឹងអ្នកត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្មក្នុងនាមជាភ័ស្តុតាងបង្ហាញថា ចម្លើយត្រូវបានទទួលពីការធ្វើទារុណកម្ម"[78]។ ពួកគេក៏សន្និដ្ឋានថា "ការប្រើប្រាស់ភ័ស្តុតាងដែលបានពីទារុណកម្ម សំដៅទទួលបានភ័ស្តុតាង [...] ពង្រីកដោយមិនមានការអនុញ្ញាតនូវករណីលើកលែងដ៏តូចចង្អៀតរបស់មាត្រា ១៥ និងធ្វើឱ្យខកគោលបំណងរបាំង"[79] ហើយ "[ការសំអាងលើ] ភ័ស្តុតាងបានពីទារុណកម្មក្នុងកិច្ចដំណើរការនីតិវិធីនឹងផ្ដល់ភាពស្របច្បាប់ដល់ការធ្វើទារុណកម្ម" និង "ធ្វើឱ្យខូចខាតដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងនោះ"[80]។

25. សហមេធាវីការពារក្ដីចុងក្រោយបានជំទាស់ថា "ការធ្វើមោឃភាពគឺជាដំណោះស្រាយដ៏សមស្រប" ដោយសារ "សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ត្រូវបានរំលោភបំពានថតាមរយៈការប្រើប្រាស់ដោយខុសច្បាប់នូវភ័ស្តុតាងបានពីទារុណកម្ម" ហើយថា "កិច្ចដំណើរការនីតិវិធីគឺមិនមានយុត្តិធម៌ឡើយនៅពេលដែលកិច្ចដំណើរការនីតិវិធីនេះមិនត្រូវបានធ្វើឡើងស្របតាមធម្មនុញ្ញកម្ពុជា និងមាត្រា ១៥ នៃអនុសញ្ញា CAT"[81] ។ ពួកគេបន្ថែមថា "ការប្រើប្រាស់វិធីសាស្ត្រដែលមានភាពបត់បែនចំពោះការប្រើប្រាស់ភ័ស្តុតាងបានពីទារុណកម្ម និងភ័ស្តុតាងដែលទទួលបានពីភ័ស្តុតាងបានពីទារុណកម្ម" "បង្កផលប៉ះពាល់អវិជ្ជមាន [...] លើសិទ្ធិបុគ្គលក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ [...] ប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងរដ្ឋបាលនៃយុត្តិធម៌អន្តរជាតិនៅ អ.វ.តក"[82] ។

## ខ. ការពិភាក្សា

26. អង្គបុរេជំនុំជម្រះសូមយោងលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការទារុណកម្មដែលចែងថា៖

> "រាល់រដ្ឋភាគីនីមួយៗត្រូវធានាថា ចម្លើយទាំងឡាយណាដែលត្រូវបានបង្ហាញភ័ស្តុតាងថាបានបង្កើតឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្មមិនត្រូវលើកយកមកធ្វើជាភ័ស្តុ

---

[78] ការឆ្លើយតប កថាខណ្ឌ ៤៦។

[79] ការឆ្លើយតប កថាខណ្ឌ ៥០។

[80] ការឆ្លើយតប កថាខណ្ឌ ៥៧ កថាខណ្ឌ ៥៩។

[81] ការឆ្លើយតប កថាខណ្ឌ ៦២ (ឯកសារយោង រំលង)។

[82] ការឆ្លើយតប កថាខណ្ឌ ៦៣។

តាងនៅក្នុងកិច្ចដំណើរការនីតិវិធីនោះទេលើកលែងតែប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទការធ្វើទារុណកម្មដើម្បីបង្ហាញជាភស្តុតាងថាចម្លើយនោះត្រូវបានធ្វើឡើង"។

27. អង្គបុរេជំនុំជម្រះបានរកឃើញថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក[83] ហើយមាត្រានេះត្រូវអនុវត្តឱ្យបានតឹងរ៉ឹង[84]។ អង្គបុរេជំនុំជម្រះត្រូវអានមាត្រា ១៥ ឱ្យស្របទៅតាមអត្ថន័យដើមនៃបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មនៅក្នុងបរិបទរបស់វា ហើយដោយពិចារណាលើកម្មវត្ថុ និងគោលបំណងរបស់វា[85]។ អង្គបុរេជំនុំជម្រះយល់ស្របថា "អនុសញ្ញាប្រឆាំងការធ្វើទារុណកម្មបានកំណត់ពីកម្មវត្ថុ និងគោលបំណងរបស់ខ្លួនក្នុងការទទួលស្គាល់សិទ្ធិមនុស្សដែលមិនអាចដកហូតបាន និងសេចក្ដីថ្លៃថ្នូរដែលមានជាប់ជាមួយនឹងបុគ្គលម្នាក់ៗ"[86]។

[83] សំណុំរឿង ០០២ (អ.ប.ជ ៣១) សាលដីកាសម្រេចលើការទទួលយកបណ្ដឹងរបស់លោក អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និតរបស់ ក.ស.ច.ស លើសំណើសុំរបស់លោក អៀង សារី ទាក់ទងនឹងការទទួលស្គាល់របស់ ក.ស.ច.ស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលបានទទួលតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D130/7/3/5 ("សាលដីកា អ.ប.ជ លើសំណុំរឿង ០០២") កថាខណ្ឌ ៣៥។ *សូមមើលផងដែរ* សេចក្ដីសម្រេច អ.ជ.ត.ក ក្នុងសំណុំរឿង ០០២ លើការជំទាស់ទៅនឹងបញ្ជីឯកសារ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ F26/12 ("សេចក្ដីសម្រេចរបស់តុលាការកំពូល") លេខយោងជើងទំព័រ ៦៥ ដែលយោងលើ ក្រុមប្រឹក្សាធម្មនុញ្ញ សំណុំរឿងលេខ ១៣១/០០៣/២០០៧ សេចក្ដីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ និងដែលយោងលើសេចក្ដីសង្កេតសរុបរបស់គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម (ប្រទេសកម្ពុជា) CAT/C/KHM/CO/2 ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ១០។

[84] សាលដីកា អ.ប.ជ លើសំណុំរឿង ០០២ កថាខណ្ឌ ៣៨។ *សូមមើលផងដែរ* គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម យោបល់ទូទៅលេខ ២ ការអនុវត្តមាត្រា ២ ដោយយោបល់ទូទៅ/អនុសាសន៍របស់រដ្ឋភាគី CAT CAT/C/GC/2 ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ កថាខណ្ឌ ៦៖ "គណកម្មាធិការនេះបានបញ្ជាក់ថា កាតព្វកិច្ចនៅក្នុងមាត្រា [...] ១៥ (ហាមឃាត់ចម្លើយសារភាពដែលទាញចេញពីការធ្វើទារុណម្មមិនឲ្យទទួលយកមកធ្វើជាភស្តុតាងលើកលែងប្រឆាំងនឹងអ្នកធ្វើទារុណកម្មខ្លួនឯង) [...] "*ត្រូវគោរពនៅគ្រប់កាលៈទេសៈទាំងអស់*"។ សូមមើលផងដែរ សាលដីកា អ.ប.ជ លើសំណុំរឿង ០០២ កថាខណ្ឌ ៤០ "ការបកស្រាយនៃ [...] មាត្រា ១៥ ដែលនឹងធ្វើឲ្យទាន់ខ្សោយការហាមឃាត់ និងការការពារទារុណកម្មត្រូវ [...] ច្រានចោល" ។

[85] មាត្រា ៣១ អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញាដែលត្រូវបានអនុម័តនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ និងចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០ សេរីសន្ធិសញ្ញាអង្គការសហប្រជាជាតិ វ៉ុល ១១៥៥ ("អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា")។

[86] សាលដីកា អ.ប.ជ លើសំណុំរឿង ០០២ កថាខណ្ឌ ៤០។

28. យោងតាមករណីនេះ អង្គបុរេជំនុំជម្រះយល់ស្របថា សនិទានភាពនៅពីក្រោយវិធានបដិសេធភ័ស្តុតាងក្នុងមាត្រា ១៥ "រួមបញ្ចូលគោលនយោបាយសាធារណៈនៃការមិនលើកទឹកចិត្តឱ្យមានការធ្វើទារុណកម្មមិនថានៅទីណាក្នុងពិភពលោកដោយជម្រុញភ្នាក់ងារអនុវត្តច្បាប់កុំឱ្យប្រើប្រាស់ទារុណកម្ម។ ម្យ៉ាងវិញទៀត ចម្លើយសារភាព និងព័ត៌មានផ្សេងទៀតដែលទាញយកបានដោយការធ្វើទារុណកម្ម ឬការធ្វើបាប ពុំត្រូវបានចាត់ទុកថាអាចទុកចិត្តបានជាប្រភពភ័ស្តុតាងនៅក្នុងកិច្ចដំណើរការនីតិវិធីច្បាប់នោះទេ។ ចំណុចចុងក្រោយ ការទទួលយកវាគឺជាការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ"[87]។

### ១. ឧទ្ទិករណ៍អំពីភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

29. សហមេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍តវ៉ាថា ព័ត៌មានដែលបានប្រើប្រាស់ជាតម្រុយនៃការស៊ើបអង្កេតគឺជាភ័ស្តុតាងដោយសារថាវាគឺជាចំណងទាក់ទងនៅក្នុងខ្សែសង្វាក់នៃភ័ស្តុតាងទំនងជាបង្ហាញ ឬ បដិសេធអង្គហេតុមួយ។ សហមេធាវីការពារក្តីយល់ឃើញថា និយមន័យនៃភ័ស្តុតាងដែលដកចេញតម្រុយនៃកិច្ចស៊ើបសួរ គឺមានលក្ខណៈចង្អៀតពេក ហើយមិនអាចត្រូវបានប្រើប្រាស់ដើម្បីគេសវេសមិនគោរពតាមវិធានបដិសេធភ័ស្តុតាង ដូចមានចែងនៅក្នុងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មនោះទេ។ និយាយឱ្យជាក់លាក់ជាងនេះ "ឈ្មោះ និងអាសយដ្ឋានក្នុងជីវប្រវត្តិ ស-២១ គឺជាចំណងភ្ជាប់នៃខ្សែចង្វាក់ដែលបាននាំឱ្យអ្នកស៊ើបអង្កេតបានស្តាប់ចម្លើយសាក្សី។ បើគ្មានជីវប្រវត្តិដែលទទួលបានមកពីទារុណកម្មទាំងនេះទេ អ្នកស៊ើបអង្កេតនឹងមិនអាចដឹងពីសាក្សីសក្តានុពលទាំងនេះ ឬអាចប្រមូលកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ពួកគេបានឡើយ"[88]។

---

[87] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬ ការដាក់ទណ្ឌកម្មអមនុស្សធម៌ផ្សេងទៀត ឬ បន្ថោកបន្ទាប Juan E Méndez U.N.G.A ក្រុមប្រឹក្សាសិទ្ធិមនុស្ស សម័យប្រជុំលើកទី ២៥ ឯកសារលេខ អ.ស.ប A/HRC/25/60 ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ (របាយការណ៍នៃអ្នករាយការណ៍ពិសេស ស្តីពីទារុណកម្ម") កថាខណ្ឌ ២១។ សូមមើលផងដែរ សាលដីកា អ.ប.ជ លើសំណុំរឿង ០០២ កថាខណ្ឌ ៤០ ដល់ កថាខណ្ឌ ៤៦។ សំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 ("សេចក្តីសម្រេចអង្គជំនុំជម្រះសាលដំបូង") កថាខណ្ឌ ៧៣។

[88] សំណើសុំ កថាខណ្ឌ ៨។

30. អង្គបុរេជំនុំជម្រះយល់ឃើញថា ជាទូទៅ ពាក្យ "គម្រុយនៃកិច្ចស៊ើបសួរ" ពុំគ្របដណ្តប់នៅក្នុងអត្ថន័យដើមនៃភស្តុតាងនោះទេ[89]។ គម្រុយនៃកិច្ចស៊ើបសួរពុំបង្ហាញ ឬ បដិសេធអង្គហេតុណាមួយដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅក្រោមកិច្ចស៊ើបសួរនោះទេ។ ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីថា វាគឺជា "ចំណងទាក់ទង" ឬ ការប្រើប្រាស់ឃ្លាភ្ជាប់ថា "ក៏ប៉ុន្តែសម្រាប់" ក៏ជាសញ្ញាបញ្ជាក់ថា គម្រុយនោះពុំមែនជាភស្តុតាងនោះទេ។

31. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ អ្នកស៊ើបអង្កេតទទួលភារកិច្ចពី ស.ច.ស.អ ក្នុងការកំណត់អត្តសញ្ញាណ ស្វែងរក និងស្តាប់ចម្លើយសាក្សី។ អ្នកស៊ើបអង្កេតបានប្រើប្រាស់ជីវប្រវត្តិ ស-២១ ដើម្បីស្វែងរកព័ត៌មានដូចជាទីកន្លែងកំណើត និង/ឬ ឈ្មោះសមាជិកគ្រួសារបុគ្គល ("ព័ត៌មាន") ដែលមានជីវប្រវត្តិកត់ត្រានៅ ស-២១។ បន្ទាប់មក អ្នកស៊ើបអង្កេតបានធ្វើដំណើរទៅតាមទីកន្លែងកំណើតទាំងនោះ និង/ឬ ទៅភូមិនៅជិតៗទីនោះ និងជួបជាមួយនឹងប្រធានភូមិ ឬ សាច់ញាតិដើម្បីអាចស្វែងរកទីតាំងសមាជិកគ្រួសារដែលអាចផ្តល់សក្ខីកម្ម និង ប្រសិនបើរកឃើញ ធ្វើការស្តាប់ចម្លើយអ្នកទាំងនេះ។ អ្នកស៊ើបអង្កេតច្បាស់ណាស់ពុំបានប្រើប្រាស់ព័ត៌មាន ដូចជា ទីកន្លែងកំណើត ឬ ឈ្មោះសមាជិកគ្រួសារដើម្បីបង្ហាញអង្គហេតុដែលត្រូវបានចោទប្រកាន់នោះទេ។ ព័ត៌មាននេះគ្រាន់តែយកមកធ្វើជាចំណុចចាប់ផ្តើមដើម្បីស្វែងរកសាក្សីសក្តានុពលដោយពុំបានផ្ទៀងផ្ទាត់លើគុណភាព ឬ ភាពអាចទុកចិត្តបាននៃសាក្សី ហើយជាការពិតណាស់ពុំនាំទៅដល់ការបង្កើតកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលចោទជាបញ្ហានេះទេ។ ក្នុងន័យនេះ អង្គជំនុំជម្រះយល់ស្របថា "នៅក្នុងដំណើរការនៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមិនត្រូវធ្វើការច្រានចោលសម្មតិកម្មណាមួយឡើយ ហើយវាមិនមែនជាការចាំបាច់ទេ ដែលសហចៅក្រមស៊ើបអង្កេតត្រូវប្រកាន់យកអ្វីដែលមាននៅក្នុងចម្លើយសារភាព ដើម្បីបង្កើតរបៀបរបបថ្មីក្នុងការស្វែងរកការពិត។ ធ្វើដូច្នេះ មិនប៉ះពាល់ដល់បូរណភាពនៃនីតិវិធីនោះឡើយ"[90]។

32. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រើប្រាស់ព័ត៌មានបែបនេះពីជីវប្រវត្តិ ស-២១ ពុំចាត់ទុកថាជា "ការប្រើប្រាស់ជាភស្តុតាង" នៅក្នុងអត្ថន័យដើមនៃឃ្លាដូចមានចែងនៅក្នុងមាត្រា

---

[89] Black's Law Dictionary ភស្តុតាង ១. អ្វីក៏ដោយ (រួមទាំងសក្ខីកម្ម ឯកសារ និងភស្តុតាងរូបិយ)ដែលទំនងជាបង្ហាញ ឬ បដិសេធអត្ថិភាពនៃអង្គហេតុដែលត្រូវបានចោទប្រកាន់។

[90] សំណើសុំរឿង ០០២ ក.ស.ច.ស ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬ ដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ E3/1555 កថាខណ្ឌ ២៦។



PRE-TRIAL CHAMBER * E.C.C.C *

១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនោះទេនៅពេលបកស្រាយស្របតាមបទដ្ឋានស្តីពីការបកស្រាយដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ[91]។ ក្នុងន័យនេះ អង្គជំនុំជម្រះយល់ឃើញថា និយមន័យស្តីពីភ័ស្តុតាងរបស់សហមេធាវីការពារក្តីដែលរួមបញ្ចូលតម្រុយនៃកិច្ចស៊ើបសួរ គឺជានិយមន័យទូលាយពេក។

33. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា រឿងក្តីបច្ចុប្បន្នពុំពាក់ព័ន្ធនឹងបទចោទនៃការធ្វើទារុណកម្មនោះទេ។ ព័ត៌មានត្រូវបានប្រើប្រាស់ដើម្បីធ្វើជាតម្រុយសម្រាប់កំណត់អត្តសញ្ញាណ និងកំណត់ទីតាំងសាក្សីថ្មីដោយសារពួកគេទំនងជាមានការដឹងឮដាច់ដោយឡែកពាក់ព័ន្ធនឹងបទចោទនៃការធ្វើទារុណកម្មដែលអាចជួយចូលរួមចំណែកក្នុងការស្វែងរកការពិតអំពីការចោទប្រកាន់លើការធ្វើទារុណកម្ម។ ហេតុដូច្នេះ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ការដកចេញតម្រុយនៃកិច្ចស៊ើបសួរដោយចាត់ទុកវាថាជា “ភ័ស្តុតាង” គឺផ្ទុយនឹងកម្មវត្ថុ និងគោលបំណងនៃមាត្រា ១៥ ក្នុងអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មដោយសារវាអាចនឹងធ្វើឱ្យប៉ះពាល់លើហេតុផលសមហេតុផលនៅពីក្រោយវា។

## ២. ទឡ្ហីករណ៍ស្តីពីភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម

34. សហមេធាវីការពារក្តីផ្តល់ទឡ្ហីករណ៍តវ៉ាថា ការពិនិត្យមើលឡើងវិញលើការងារព្រាងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ពុំគាំទ្រដល់ការសន្និដ្ឋានថា មានចេតនាដកភ័ស្តុតាងដែលទាញចេញការធ្វើទារុណកម្មចេញពីអនុសញ្ញានេះឡើយ ហើយករណីដែលថា ប្រព័ន្ធច្បាប់ស៊ីវិលឡូគាំទ្រការទទួលយកភ័ស្តុតាងដោយសេរីពុំមានន័យថា ប្រព័ន្ធបែបនេះអនុញ្ញាតនៅទូទាំងសាកលលោកឱ្យទទួលយកភ័ស្តុតាងដែលទាញចេញពីភ័ស្តុតាងទទួលបានពីការធ្វើទារុណកម្មនោះទេ ព្រមទាំង ការពិនិត្យមើលឡើងវិញលើប្រភពអន្តរជាតិបង្ហាញថា វិធានបដិសេធភ័ស្តុតាងអនុវត្តលើភ័ស្តុតាងដែលទាញចេញពីការធ្វើទារុណកម្ម[92]។ សហមេធាវីការពារក្តីបន្ថែមទៀតថា ហេតុផលគោលនយោបាយនៅពីក្រោយអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មបង្ហាញថា ចេតនានោះគឺចង់ដាក់បញ្ចូលភ័ស្តុតាងដែលទាញចេញពីការធ្វើទារុណកម្មនៅក្នុងវិសាលភាពនៃមាត្រា ១៥[93]។

[91] មាត្រា ៣១ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា។

[92] សំណើសុំ កថាខណ្ឌ ១៨។

[93] សំណើសុំ កថាខណ្ឌ ២១ *ដែលយោងលើ* “ទឡ្ហីករណ៍ ខ”។

35. ចំណុចទីមួយ អង្គបុរេជំនុំជម្រះយល់កត់សម្គាល់ឃើញថា សហមេធាវីការពារក្តីទទួលស្គាល់ថា មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មពុំមានចែងអំពីភស្តុតាងដែលទាញចេញពីទារុណកម្មនោះឡើយ[94]។ មាត្រានេះគ្រាន់តែសំដៅលើ "*ចម្លើយ*ណាមួយដែលត្រូវបានបង្ហាញភស្តុតាងឃើញថាត្រូវបានបង្កើតឡើងដោយសារ*លទ្ធផលនៃទារុណកម្ម*" [គូសបញ្ជាក់បន្ថែម] ដោយពុំបានធ្វើការបញ្ជាក់ឲ្យបានច្បាស់ជាងនេះ។ ការអានមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការពិនិត្យមើលឡើងវិញលើសេចក្តីព្រាងមួយចំនួន[95]នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មដែលត្រូវបានពិភាក្សានៅក្នុងដំណើរការនៅមុនពេលអនុម័តជាឯកច្ឆ័ន្ទដោយមហាសន្និបាតអង្គការ អ.ស.ប នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤[96] បង្ហាញថា ពាក្យ "ដែលទាញចេញពី" ហាក់ដូចជាឃើញមានតែម្តងគត់នៅក្នុងសេចក្តីព្រាងដំបូងស្តីពី IAPL ដែលចែងថា "ការទទួលបានដោយមធ្យោបាយនៃការធ្វើទារុណកម្ម ឬ *ភស្តុតាងណាផ្សេងដែលទាញចេញពីនោះ*" [គូសបញ្ជាក់បន្ថែម] សបញ្ជាក់ថា ការសម្រេចចុងក្រោយលើបញ្ហានេះថាតើចម្លើយជាក់លាក់ត្រូវបាន "ធ្វើឡើងដោយសារលទ្ធផលនៃទារុណកម្ម" ដែរឬយ៉ាងណានោះ ត្រូវបានទុកឲ្យអាជ្ញាធរតុលាការពិនិត្យពិច័យនៅពេលណាអាជ្ញាធរតុលាការប្រឈមនឹងការចោទប្រកាន់ជាក់លាក់នេះ។ ហេតុដូច្នេះ ការចោទប្រកាន់ជាក់លាក់ថា ចម្លើយទាំងនោះអាចស្ថិតនៅក្នុងវិសាលភាពនៃវិធានស្តីពីការបដិសេធភស្តុតាងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មត្រូវយកមកសម្រេចទៅតាមករណីនីមួយៗតាមរយៈការបកស្រាយលើពាក្យ "ដែលត្រូវបានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម" ទៅតាមបរិបទរបស់វា ហើយដោយពិចារណាទៅលើកម្មវត្ថុ និងគោលបំណង មិនមែនដោយសម្រេចថាតើ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មអនុវត្តចំពោះ "ភស្តុតាងដែលទាញចេញពីការធ្វើទារុណកម្ម" ជាទូទៅ ដែរឬយ៉ាងណានោះឡើយ។

36. នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះសង្កេតឃើញ និងយល់ស្របជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា បទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹង "ភស្តុតាងដែលបានទទួលមកពីការធ្វើ

[94] សំណើសុំ កថាខណ្ឌ ២១ និងចម្លើយតប កថាខណ្ឌ ៣៥។

[95] E/CN.4/NGO/213 (សេចក្តីព្រាង IAPL ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៨)។ E/CN.4/1285 (សេចក្តីព្រាងដើមរបស់ស៊ុយអែត ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៨)។ E/CN.4/1314 (សេចក្តីព្រាងសហរដ្ឋអាមេរិក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៨)។ និង E/CN.4/WG.1/WP.1 (កំណែសេចក្តីព្រាងស៊ុយអែត ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៧៩)។

[96] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ ៣៩/៤៦ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤។

ទារុណកម្ម" ពុំត្រូវបានបង្ហាញភ័ស្តុតាងឲ្យឃើញនោះទេ[97]។ ឯកសារសំអាងដែលបានដកស្រង់ដោយសហមេធាវីការពារក្តី[98] ដែលអះអាងថាគាំទ្រទឡ្ហីករណ៍របស់ពួកគេ ផ្ទុយពីការលើកឡើងខាងលើនោះគឺគ្រាន់តែជា "អនុសាសន៍" សម្រាប់ប្រទេសនានាចែងបញ្ចូលមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មទៅក្នុងច្បាប់ជាតិរបស់ពួកគេប៉ុណ្ណោះ ដែលមិនអាចផ្ទុយនឹងពាក្យពេចន៍ត្រង់ៗនៃមាត្រា ១៥ ប្រសិនបើមិនពិចារណាលើកាលៈទេសៈជាក់លាក់នៅក្នុងរឿងក្តីនីមួយៗទេនោះ។ របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម[99] ដែលយោងដោយសហមេធាវីការពារក្តីដែលលើកឡើងអំពីការពង្រីកវិសាលភាពវិធានស្តីពីការបដិសេធភ័ស្តុតាងក្រោយមកបានទទួលនាពេលក្រោយមកតាមរយៈមធ្យោបាយផ្លូវច្បាប់ ប៉ុន្តែដែល "បានកើតចេញនៅក្នុងអំពើនៃការធ្វើទារុណកម្ម" ក៏ជាអនុសាសន៍ទូទៅជូនស្ថាប័នតុលាការរបស់រដ្ឋដែលស្នើសុំករណីពង្រីកវិសាលភាពនេះ "ឲ្យ*លើសដែនកំណត់នៃពាក្យពេចន៍ទូទៅនៅក្នុង*មាត្រា ១៥ នៃអនុសញ្ញា ហើយផ្តល់នីតិវិធីក្នុងច្បាប់ជាតិដើម្បីដកចេញភ័ស្តុតាងណាមួយ និងភ័ស្តុតាងទាំងអស់ដែលបានទទួលដោយសារការរំលោភលើការធានាដែលត្រូវបានបង្កើតឡើងដើម្បីការពារប្រឆាំងនឹងការធ្វើទារុណកម្ម"[100]។

37. អង្គបុរេជំនុំជម្រះពិចារណាឃើញថា យោងតាមអត្ថន័យដើមរបស់វា ពាក្យ "ធ្វើឡើងដោយសារលទ្ធផល" ទាមទារនូវចំណងទាក់ទងក្នុងកម្រិតជាក់លាក់មួយ។ វាពុំរួមបញ្ចូលគ្រប់ហេតុការណ៍ដែលកើតឡើងបន្ទាប់នោះទេ។ នៅក្នុងរឿងក្តីបច្ចុប្បន្ន ចំណងទាក់ទងរវាងទារុណកម្ម និងកំណត់ហេតុនៃការស្តាប់ចម្លើយដែលចោទជាបញ្ហានេះមិនរឹងមាំនោះទេ។ ទោះបីជាការស្រាវជ្រាវរកសាក្សីត្រូវបានផ្តួចផ្តើមឡើងពីព័ត៌មាន ដូចជា ទីកន្លែងកំណើតរបស់ជនជាប់ឃុំនៅ ស-២១ ឬឈ្មោះសាច់ញាតិក៏ដោយ ក៏សាក្សីដែលចោទជាបញ្ហានេះនៅទីបំផុតត្រូវបានរកឃើញតាមរយៈការ

---

[97] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៩។

[98] សំណើសុំ កថាខណ្ឌ ២៤ *ដែលយោងលើ*កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី២៥០ ត្រង់ផ្នែកជាសាធារណៈ៖ ប្រទេសហ្វាំងឡង់ ឯកសារ អ.ស.ប លេខ CAT/C/SR.250 ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៩៦ អនុសាសន៍ កថាខណ្ឌ ១៨ ទំព័រ ៧ និង*ដែលយោងលើ*កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី២៧៩ ត្រង់ផ្នែកជាសាធារណៈ៖ ប្រទេសហ្សកហ្សីប្រទេសប៉ូឡូញ ឯកសារ អ.ស.ប លេខ CAT/C/SR.279 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៧ អនុសាសន៍ កថាខណ្ឌ ១៥ ទំព័រ ៣ និង*ដែលយោងលើ*កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី៣២៩ ត្រង់ផ្នែកជាសាធារណៈ៖ ប្រទេសអាល្លឺម៉ង់ ឯកសារ អ.ស.ប លេខ CAT/C/SR.329 ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៨ អនុសាសន៍ កថាខណ្ឌ ១៥ ទំព័រ ៨។

[99] សំណើសុំ កថាខណ្ឌ ២៥ *ដែលយោងលើ*របាយការណ៍ស្តីពីអ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម កថាខណ្ឌ ២៩។

[100] របាយការណ៍ស្តីពីអ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម កថាខណ្ឌ ៦៨ (ការគូសបញ្ជាក់បន្ថែម)។

01548586



ព្យាយាមស្រាវជ្រាវយ៉ាងហ្មត់ចត់ដោយអ្នកស៊ើបអង្កេតនៅតាមទីកន្លែងនានា។ កិច្ចស្តាប់ចម្លើយត្រូវបានធ្វើឡើងដោយអាស្រ័យលើភាពទំនេរ និងការស្ម័គ្រចិត្តរបស់សាក្សី។ ព័ត៌មាននេះត្រូវបានទាញយកចេញពីទំព័រខាងមុខគេនៃជីវប្រវត្តិ ស-២១[101] ដែលពុំពាក់ព័ន្ធនឹងខ្លឹមសារនៃចម្លើយសារភាពនៅ ស-២១ នោះទេ ដែលវាត្រូវបានសន្មតថាបានធ្វើឡើងក្រោមទារុណកម្ម[102]។ នៅក្នុងកាលៈទេសៈទាំងនេះ កម្រិតនៃចំណងទាក់ទងពុំគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា កំណត់ហេតុនៃការស្តាប់ចម្លើយដែលចោទជាបញ្ហានេះ "ត្រូវបានធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម" ស្របតាមអត្ថន័យដើមនៃឃ្លានេះដូចបានប្រើប្រាស់នៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម។

38. អង្គបុរេជំនុំជម្រះក៏យល់ឃើញផងដែរថា នៅក្នុងរឿងក្តីនេះ ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលថា ការប្រើប្រាស់ភស្តុតាងដែលបានទទួលមកពីទារុណកម្មដើម្បីទទួលបានចម្លើយទាញចេញពីការធ្វើទារុណកម្ម ពង្រីកដោយមិនមានការអនុញ្ញាតនូវករណីលើកលែងដ៏តូចចង្អៀតរបស់មាត្រា ១៥ និងធ្វើឱ្យខកគោលបំណងរារាំងនោះ ពុំត្រឹមត្រូវឡើយ ដោយសារចំណុចទីមួយ ការបកស្រាយឃ្លា "ចម្លើយ [...] ដែលធ្វើឡើងដោយសារលទ្ធផលនៃការធ្វើទារុណកម្ម" នៅក្នុងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មពុំពាក់ព័ន្ធនឹងអញ្ញត្រកម្មនៃមាត្រានេះ ហើយចំណុចទីពីរការបកស្រាយក្នុងន័យទូលាយរបស់សហមេធាវីការពារក្តីលើសពីអត្ថន័យដើមនៃឃ្លារបស់វាផ្ទុយពីហេតុផលនៅពីក្រោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មប្រសិនបើការស៊ើបអង្កេតនៃការចោទប្រកាន់លើការធ្វើទារុណកម្មត្រូវបានរារាំង ហើយអ្នកដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មត្រូវបានការពារដោយការបកស្រាយនេះ[103]។

39. សរុបមក អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍របស់សហមេធាវីការពារក្តីដែលថា កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលចោទជាបញ្ហា មានវិការៈនោះ ពុំត្រឹមត្រូវឡើយ។

---

[101] សេចក្តីសម្រេចតុលាការកំពូល កថាខណ្ឌ ៦៨៖ "មិនថាព័ត៌មានដូចជាជីវប្រវត្តិដែលបានកត់ត្រានៅក្នុងចម្លើយសារភាព ស-២១ ឬ កំណត់ត្រាគុកកំណត់អត្តសញ្ញាណជនរងគ្រោះ ដូចជា ឈ្មោះពួកគេ អាយុ អាសយដ្ឋាន នាទីពីមុន និងអង្គភាព ឬ តួនាទីក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ [...] ត្រូវបានទទួលដោយការធ្វើទារុណកម្មគឺជាបញ្ហានៃការបង្ហាញភស្តុតាង"។

[102] សេចក្តីសម្រេចតុលាការកំពូល កថាខណ្ឌ ៥៧៖ "មានហានិភ័យជាក់ស្តែងថា ចម្លើយ ស-២១ ត្រូវបានទទួលតាមរយៈការធ្វើទារុណកម្ម ហើយចម្លើយនីមួយៗអាចត្រូវបានសន្មតថាត្រូវបានទទួលតាមរយៈករណីនេះ"។

[103] *ដូចខាងលើ* កថាខណ្ឌ ៣៣។

## IV. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយោងតាមសម្លេងជាឯកច្ឆន្ទ៖**

**យល់ឃើញថា** សំណើសុំនេះអាចទទួលយកបានតាមទម្រង់ច្បាប់។

**ច្រានចោល**សំណើសុំនេះលើអង្គសេចក្តីទាំងស្រុង។

យោងតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន Olivier BEAUVALLET **ន័យ ថុល** Kang Jin BAIK **ហួត វុទ្ធី**